ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ២ លេខ : ១០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

សកម្មភាព ការងារ

ECOSOCC



Work Activities

ក ស វ

ប្រចាំខែ តុលា ឆ្នាំ ២០០៩



# មាតិកាអត្ថបទ

## កិច្ចប្រជុំទី២ រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាផ្នែកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល

**ល.រ ឈ្មោះអត្ថបទ**


១. សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ........ ១–២

២. សេចក្តីព្រាងច្បាប់ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ........ ៣–៤

៣. កិច្ចប្រជុំបន្តលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់យានយន្ត និងប្រភេទផ្លាកលេខយានយន្ត ........ ៥

៤. ប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព ........ ៦

៥. កិច្ចប្រជុំផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ........ ៧–៨

៦. សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ........ ៩–១៣

## សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពី

# ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## និងសេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

កាលពីថ្ងៃទី០៦, ០៧ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ១៥:០០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្ដម **ឃឹម ឈុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្ដម **អ៊ុក ឆ្វារិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្ដីការគណៈរដ្ឋមន្ត្រី។



ក្រុមប្រឹក្សាជាតិដើម្បីកុមារត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងតាមអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ និងលេខ៥៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ស្របតាមស្ថានភាពការងារកុមារប៉ុន្មានឆ្នាំកន្លងទៅ ហើយបច្ចុប្បន្នស្ថានភាពកុមារមានការវិវត្តគួរឲ្យកត់សម្គាល់ អត្រាកុមារមាន៩១ ភាគរយនៃចំនួនប្រជាជនសរុប តាមការរឿនឆ្នាំ២០០៨។ ផ្អែកតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលមានចែងជាអាទិ៍ រាជរដ្ឋាភិបាលការពារលើកស្ទួយសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ និងពង្រឹងការងារសុខុមាលភាពកុមារ ដោយផ្ដល់ការគាំពារដល់កុមារងាយរងគ្រោះ ដូចជាកុមារកំព្រា កុមារពិការ កុមារនៃគ្រួសារក្រីក្រនៅតាមសហគមន៍តាមរយៈការបង្កើនការអប់រំ ការស្ដារនីតិសម្បទានិងការបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់កុមារងាយរងគ្រោះ ការទប់ស្កាត់ការធ្វើអាជីវកម្មតាមគ្រប់រូបភាពចំពោះកុមារ និងដើម្បីឲ្យស្របតាមការអភិវឌ្ឍ



របស់ប្រទេសជាតិ អនុក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅមានចំណុចខ្វះខាតមួយចំនួនសម្រាប់អនុវត្តនាពេលបច្ចុប្បន្ន ដូចជាពុំមានរចនាសម្ព័ន្ធជំនួយការ ដូចជាអគ្គលេខាធិការដ្ឋាន ការគ្រប់គ្រងមន្ត្រីជាដើម ដែលទាមទារធ្វើការកែសម្រួលថ្មីឡើងវិញទៅជា ព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងស្របពេលជាមួយគ្នានេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំនូវសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារតែម្តង[១] ។

អង្គប្រជុំបានឯកភាពពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ហើយបានធ្វើការកែសម្រួលខ្លឹមសារមួយចំនួន ដើម្បីធ្វើឲ្យសេចក្តីព្រាងទាំងនេះកាន់តែល្អប្រសើរ។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះ៕

[១] អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុ នៃសេចក្តីព្រាងព្រះរាជ ក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

### សេចក្តីព្រាងច្បាប់ស្តីពី

# ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន នៃអគារសហកម្មសិទ្ធិ ដល់ជនបរទេស

កាលពីថ្ងៃទី១៥, ២៦, ២៧ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន** នៃអគារសហកម្មសិទ្ធិ ដល់ជនបរទេស ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។





អនុលោមទៅតាមការវិវឌ្ឍរីកចម្រើនរបស់ប្រទេសជាតិ និងការកើនឡើងលើវិស័យដីធ្លី ជាពិសេសការអភិវឌ្ឍលើវិស័យសំណង់អគារខ្ពស់ៗក្នុងព្រះរាជាណាចក្រកម្ពុជា និងយោងទៅតាមស្មារតីនៃអង្គប្រជុំក្រុមការងារផ្នែកនីតិកម្មពន្ធដារ និងអភិបាលកិច្ច (ក្រុម ឃ) នៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន ឆ្នាំ២០០៧ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន នៃអគារសហកម្មសិទ្ធិ ដល់ជនបរទេស ដើម្បីសម្រួលដល់ធុរៈជន និងវិនិយោគគិនដែលមកដាក់ទុនវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់នេះមានគោលដៅផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន នៃអាគារសហកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់ចំណែករួមនៃអគារសហកម្មសិទ្ធិ ដល់ជនបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការទទួលបាននូវសិទ្ធិនេះ ជាពិសេស សម្រាប់ជនបរទេសដែលរាជរដ្ឋាភិបាលយល់ឃើញថាមានប្រយោជន៍ចំពោះព្រះរាជាណាចក្រកម្ពុជា។ ការផ្តល់កម្មសិទ្ធិនេះ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតែប៉ុណ្ណោះ (ចាប់ពីជាន់ទី០១ ឡើងទៅ)។ ចំពោះចំណែករួមនៃអគារសហកម្មសិទ្ធិ សហកម្មសិទ្ធិករបរទេសមិនមានសិទ្ធិកម្មសិទ្ធិឡើយ គឺមានត្រឹមតែសិទ្ធិប្រើប្រាស់ និងអាស្រ័យផលប៉ុណ្ណោះ (មិនមានសិទ្ធិ

កម្មសិទ្ធិលើដីធ្លីឡើយ)។



សេចក្តីព្រាងច្បាប់នេះមានគោលបំណងកំណត់អំពីគោលការណ៍ទូទៅ សិទ្ធិនិងកាតព្វកិច្ចទាំងឡាយសម្រាប់ជនបរទេសដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតដែលមានទំនាក់ទំនងនឹងចំណែករួម ព្រមទាំងនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិទាំងនោះ។

តាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ភូមិបាល គឺមិនបានអនុញ្ញាតឲ្យជនបទបរទេសមានសិទ្ធិកម្មសិទ្ធិលើដីធ្លីទេ តែក៏មិនបានហាមឃាត់សិទ្ធិកម្មសិទ្ធិលើអគារសហកម្មសិទ្ធិដែរ (រដ្ឋធម្មនុញ្ញមាត្រា៤៤ និងច្បាប់ភូមិបាល៨)។ ទន្ទឹមនឹងនេះ ច្បាប់ភូមិបាលក៏បានទុកឱកាសក្នុងការដាក់បញ្ញត្តិបន្ថែមលើចំណុចណាមួយដែលអត្ថបទច្បាប់មិនបានលើកឡើងច្បាស់លាស់ ដោយមានចែងក្នុងមាត្រា១១ ថា " របបគតិយុត្តនៃកម្មសិទ្ធិអចលនវត្ថុ ប្រែប្រួលទៅតាមតម្រូវការរបស់សង្គមខ្មែរដូចជា ដីកសិកម្ម ព្រៃឈើ ផ្លូវទឹក... អចលនវត្ថុក្នុងទីក្រុង និងដីសម្រាប់សាងសង់តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម។ ច្បាប់ពិសេសត្រូវបំពេញបទប្បញ្ញត្តិទាំងឡាយនៃអត្ថបទច្បាប់នេះ ឬតាំងបដិប្បញ្ញត្តិដើម្បីរក្សានូវការចាំបាច់ខាងសង្គមកិច្ច ការរៀបចំដែនដី និងនគរូបនីយកម្ម "។ ដូច្នេះការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ការផ្តល់សិទ្ធិលើកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស គឺជាច្បាប់ពិសេស តាំងបដិប្បញ្ញត្តិទៅនឹងរបបកម្មសិទ្ធិទៅតាមការវិវឌ្ឍរីកចម្រើនរបស់ប្រទេសជាតិ និងការស្នើសុំរបស់ដៃគូឯកជនក្នុងការសម្រួលដល់ធុរកិច្ច និងការវិនិយោគរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនឹងរួមចំណែកដល់ការវិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេស(១) ។

អង្គប្រជុំបានឯកភាពពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ហើយបានធ្វើការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួនដូចជា ការបង្កើតមាត្រាថ្មីដើម្បីដាក់ទណ្ឌកម្មលើមន្ត្រីសុរិយោដី និងលើអ្នកទិញដែលបានប្រព្រឹត្តិខុស ការបង្កើតជំពូកថ្មីគឺ អន្តរប្បញ្ញត្តិ ដែលទុកឱកាសឲ្យអ្នកទិញមុនច្បាប់នេះចូលជាធរមាន អាចធ្វើនិយ័តកម្មក្នុងរយៈពេល ០២ឆ្នាំ និងបានធ្វើការកែសម្រួលខ្លឹមសារខ្លះៗទៀតដើម្បីឲ្យសេចក្តព្រាងច្បាប់កាន់តែល្អប្រសើរ។

អង្គប្រជុំទី១ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងច្បាប់ នេះ៕

(១)អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុលើសេចក្តីព្រាងច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដល់ជនបរទេស។

### ប្រជុំមន្ត្រីលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# នីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់យានយន្ត និងប្រភេទផ្លាកលេខយានយន្ត



កាលពីថ្ងៃទី០៨, ២០ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និងឯកឧត្តម **អ៊ុក ភូរិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់យានយន្ត និងប្រភេទផ្លាកលេខយានយន្ត** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

អង្គប្រជុំបានបន្តពិភាក្សាគ្នាយ៉ាងផុលផុសលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែលំអរធ្វើឲ្យអត្ថន័យ និងអត្ថរូបកាន់តែល្អប្រសើរ ក៏ប៉ុន្តែបានរក្សាទុកនូវចំណុចមួយចំនួនទៀត ដែលអង្គប្រជុំទី១ មិនយល់ស្របដើម្បីពិភាក្សាម្តងទៀតពេលប្រជុំអន្តរក្រសួង ដោយបានអះអាងថាៈ

–បង្កើតឲ្យមានបញ្ហាច្រើនដល់ម្ចាស់ ដូចជានគរបាលចរាចរនឹងបញ្ឈប់យានជំនិះ ហើយផាកពិន័យព្រោះខុសច្បាប់

–បង្កការលំបាកដល់ម្ចាស់កម្មសិទ្ធិមួយចំនួនដែលមានភារកិច្ចទៅបម្រើជាតិម្តងនៅខេត្តនេះ ម្តងនៅខេត្តនោះ រៀងរាល់ ០២ ឬ ០៣ឆ្នាំ ដូច្នេះគេត្រូវប្តូរផ្លាកលេខរហូត

–បើតម្រូវឲ្យធ្វើដូច្នេះគួរតែធ្វើដូចគ្នាចំពោះករណីដូចចង្កោម ទី២ និងទី៣ ដើម្បីឲ្យមានភាពស្មើសិទ្ធិគ្នានៃម្ចាស់យានជំនិះ។

អង្គប្រជុំបានបញ្ចប់ការពិភាក្សាបណ្តោះអាសន្ននៅមាត្រា២១៕



## ប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការអនុវត្តច្បាប់ស្តីពី ជីវសុវត្ថិភាព

កាលពីថ្ងៃទី១៣, ១៤, ២២, ២៣ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្តម **ឈន ឡាលីន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពី ជីវសុវត្ថិភាព** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងបរិស្ថាន សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។





បន្ទាប់ពីឆ្លងកិច្ចប្រជុំចង្អៀតរវាង ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងក្រសួងបរិស្ថាន សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសារពាង្គកាយរស់ បានដាក់ឆ្លងកិច្ចប្រជុំទី១ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ត្រូវបានប្តូរឈ្មោះទៅជា សេចក្តីព្រាងអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព ហើយមានការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួន ដែលធ្វើឲ្យសេចក្តីព្រាងនេះប្រសើរជាងសេចក្តីព្រាងដំបូង ដែលអាចពិនិត្យពិភាក្សាបាននាពេលនេះ។

អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ ដោយផ្តោតទៅលើចំណងជើងនៃសេចក្តីព្រាងនេះ ដោយខ្លាចក្រែងក្រសួងបរិស្ថានចេញអនុក្រឹត្យផ្សេងទៀតនៅថ្ងៃក្រោយ ព្រោះច្បាប់ស្តីពីជីវសុវត្ថិភាពបានចង្អុលឲ្យបង្កើតអនុក្រឹត្យមានជាច្រើនមាត្រា ហើយចំណងជើងនេះបានគ្របដណ្តប់អស់លើការអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាពអស់ហើយ។ ក៏ប៉ុន្តែអង្គប្រជុំ បានឯកភាពចំពោះចំណងជើងនេះ ក្រោយពីតំណាងក្រសួងបរិស្ថានបានអះអាងថា នាពេលអនាគតនឹងមិនមានចេញអនុក្រឹត្យផ្សេងទៀតទេ បើកាលណាអនុវត្តអនុក្រឹត្យនេះទៅមានបញ្ហាខ្វះខាត ក្រសួងនឹងស្នើសុំធ្វើវិសោធនកម្មអនុក្រឹត្យនេះ។ ក្រៅពីនេះ អង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួនទៀត។

អង្គប្រជុំបានបញ្ចប់ការពិភាក្សាបណ្តោះអាសន្ននៅជំពូកទី៣៕

# កិច្ចប្រជុំផ្ទៃក្នុងរបស់ ECOSOCC

នាថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ វេលាម៉ោង ១៥:០០ នាទី នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ក.ស.វ.) បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ លើរបៀបវីរៈដូចខាងក្រោម៖

១–ណែនាំសមាជិកថ្មី

២–ពិភាក្សាផ្ទៃក្នុងលើដំណើរការប្រចាំថ្ងៃរបស់ ECOSOCC

៣–ពិភាក្សាលើផែនការយុទ្ធសាស្ត្ររបស់ ECOSOCC

៤–ពិភាក្សាលើការស្រាចជ្រាវលើបញ្ហាប្រឈម

៥–ពិភាក្សាបញ្ហាកម្មវិធីវិទ្យុទីស្តីការគណៈរដ្ឋមន្ត្រី។





# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ តុលា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២.១០.០៩ | ចូលរួមក្នុងអង្គប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងដីចំណីតាមបណ្តោយផ្លូវថ្នល់ និងផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការកែសម្រួលតាមស្មារតីប្រជុំអន្តរក្រសួងលើកទី ២ បន្ទាប់ពីការណែនាំក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ ក្រោមអធិបតីភាព ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៨.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីរំឭកខួបអនុស្សាវរីយ៍លើកទី ៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ៣ | ៨ ,២១.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីជូន និងទទួលដំណើរមាតុភូមិនិវត្តន៍ របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ដឹកនាំគណៈប្រតិភូទៅចូលរួមមហាសន្និបាតលើកទី ៣៥ នៃអង្គការយូណេស្កូ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ |
| ៤ | ០៩.១០.០៩ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងសេចក្តីថ្លែងការណ៍ស្តីពី គោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ច ជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ។<br>២-សេចក្តីព្រាងច្បាប់ស្តីពី អស្សាមិករណ៍។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងលើការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមី។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី។<br>៥-បញ្ហាផ្សេងៗ |
| ៥ | ១៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីប្រារព្ធខួបទី ១៥ ថ្ងៃបង្កើតកងពលតូចលេខ ៧០ និងសម្ពោធអគារថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ។ |
| ៦ | ១៥-១៧.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីជូន និងទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទៅបំពេញទស្សនកិច្ចការងារ និងចូលរួមពិធីបើកពិព័រណ៍ពាណិជ្ជកម្ម និងសេដ្ឋកិច្ចអន្តរជាតិភាគខាងលិចប្រទេសចិន លើកទី ១០ ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៩ នៅទីក្រុង Chengdu ខេត្តស៊ីជាន់ នៃសាធារណរដ្ឋប្រជាមានិតចិន។ |

| | | |
|---|---|---|
| ៧ | ១៦.១០.០៩ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងលើការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមី។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី។<br>៣-បញ្ហាផ្សេងៗ |
| ៨ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីគម្រោងវិនិយោគផលិតផលស្រូវកម្ពុជា សម្រាប់នាំចេញ រវាងក្រុមហ៊ុន Green Trade និងអ្នកវិនិយោគកូរ៉េ តំណាងដោយក្រុមហ៊ុន KTC/Kyung An Cadle Co., Ltd និងធនាគារ Kookmin ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំឫស្សីជ្រោយ។ |
| ៩ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា រាជធានី-ខេត្ត របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ដោយមានការចូលរួមពីឯកឧត្តម **លី យុនហូ** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចចំណេះដឹង នៃសាធារណៈរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ២៣ ,២៥.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីជូន និងទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានពាក់ព័ន្ធនៅ ឆាយអាម-ហួហ៊ីន នៃព្រះរាជាណាចក្រថៃ។ |
| ១១ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យប្រេងកាត រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយក្រុមហ៊ុនសាជីវកម្មប្រេងកាតជាតិរបស់ប្រទេសកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២៨.១០.០៩ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពី លក្ខខណ្ឌ និងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេល នៃយុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងសមត្ថកិច្ច ក្នុងការអនុវត្តច្បាប់ ការតព្វកិច្ចយោធា។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងដីចំណីតាមបណ្តាផ្លូវថ្នល់ និងផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ |
| ១៣ | ២៩.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយក្រុមកីឡាករទូ " ង" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំឫស្សី ជ្រោយ។ |

## សកម្មភាពដទៃទៀតរបស់ ឯកឧត្តម គីម សយសាម៉ាឡែន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ តុលា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៩.១០.០៩ | ប្រជុំពិនិត្យកិច្ចដំណើរការការងាររបស់ក្រុម១ នៃក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ |
| ២ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីគម្រោងវិនិយោគផលិតផលស្រូវកម្ពុជា សម្រាប់នាំចេញ រវាងក្រុមហ៊ុន Green Trade និងអ្នកវិនិយោគកូរ៉េ តំណាងដោយក្រុមហ៊ុន KTC/Kyung An Cadle Co., Ltd និងធនាគារ Kookmin ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំឬស្សីជ្រោយ។ |
| ៣ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា រាជធានី–ខេត្ត របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ដោយមានការចូលរួមពីឯកឧត្តម **លី យុនហ្វ** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចចំណេះដឹង នៃសាធារណៈរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យប្រេងកាត រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយក្រុមហ៊ុនសាជីវកម្មប្រេងកាតជាតិរបស់ប្រទេសកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ប៊ិច ឈុន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ តុលា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២.១០.០៩ | ចូលរួមក្នុងអង្គប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងដីចំណីតាមបណ្តោយផ្លូវថ្នល់ និងផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការកែសម្រួលតាមស្មារតីប្រជុំអន្តរក្រសួងលើកទី ២ បន្ទាប់ពីការណែនាំក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ ក្រោមអតិបតីភាពឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ២៩.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយក្រុមកីឡាករទូ " ង" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំឬស្សី ជ្រោយ។ |

# សកម្មភាពផ្សេងៗទៀតរបស់ ឯកឧត្តម យឹម ឈុលសន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ កញ្ញា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីគម្រោងវិនិយោគផលិតផលស្រូវកម្ពុជា សម្រាប់នាំចេញ រវាងក្រុមហ៊ុន Green Trade និងអ្នកវិនិយោគកូរ៉េ តំណាងដោយក្រុមហ៊ុន KTC/Kyung An Cadle Co., Ltd និងធនាគារ Kookmin ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំឬស្សីជ្រោយ។ |
| ២ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា រាជធានី–ខេត្ត របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ដោយមានការចូលរួមពីឯកឧត្តម **លី យុនហូ** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចចំណេះដឹង នៃសាធារណៈរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៣.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យប្រេងកាត រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយក្រុមហ៊ុនសាជីវកម្មប្រេងកាតជាតិរបស់ប្រទេសកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៩.១០.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយក្រុមកីឡាករទូ " ង" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំឬស្សី ជ្រោយ។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម សមាជិក
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ តុលា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១ ,២៦.០៩.០៩ | ឯកឧត្តម **សូរ ជីវគុណ** ចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើពង្រាងអនុក្រឹត្យស្តីពី នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារនៈ ឬការជួយតាមការព្រមព្រៀង និងការបងថ្លៃឈ្នួលនេសាទ។ |
| ២ | ១០.១០.០៩ | ឯកឧត្តម **ឥន យឿន** រៀបចំគម្រោងសរសេរព័ត៌មានសម្រាប់វិទ្យុ ចំនួន ០២។ |
| ៣ | ១១.១០.០៩ | ឯកឧត្តម **ឥន យឿន** រៀបចំប្រធានបទសម្រាប់កម្មវិធីវិទ្យុស្តីពី ការប្រើប្រាស់អគារសហកម្មសិទ្ធិ។ |
| ៤ | ០៨ , ២១.១០.០៩ | ឯកឧត្តម **ឡេង ស្រេង** ចូលរួមជាកិត្តិយសក្នុងពិធីជូន និងទទួលដំណើរមាតុភូមិនិវត្តន៍ របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ដឹកនាំគណៈប្រតិភូទៅចូលរួមមហាសន្និបាតលើកទី ៣៥ នៃអង្គការយូណេស្កូ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ ។ |
| ៥ | ២៣.១០.០៩ | ឯកឧត្តម **ឡេង ស្រេង** ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា រាជធានី–ខេត្ត របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ដោយមានការចូលរួមពីឯកឧត្តម **លី យុនឃា** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចចំណេះដឹង នៃសាធារណៈរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ២៣.០៩.០៩ | ឯកឧត្តម **ឡេង ស្រេង** ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីគម្រោងវិនិយោគផលិតផលស្រូវកម្ពុជា សម្រាប់នាំចេញ រវាងក្រុមហ៊ុន Green Trade និងអ្នកវិនិយោគកូរ៉េ តំណាងដោយក្រុមហ៊ុន KTC/Kyung An Cadle Co., Ltd និងធនាគារ Kookmin ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅយុំឫស្សីជ្រោយ។ |
| ៧ | ២៩.១០.០៩ | ឯកឧត្តម **ឡេង ស្រេង** ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយក្រុមកីឡាករទូ " ង" ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅយុំឫស្សីជ្រោយ។ |





ប្រជុំពេញអង្គប្រចាំខែរបស់ ក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ក.ស.វ.)

# ព្រឹត្តិបត្រព័ត៌មាន

naykRKbRKgTeTA 3 ឯកឧត្តម គឹម សយសាម៉ាឡែន SmaCk k>s>v>
nBnnayk 3 ឯកឧត្តម វង្ស សំអាង GKe l xaFkar k>s>v>
nBnGtbT ngcatEcgTeTA 3 ឯកឧត្តម អេង រត្នមុនី GKe l xaFkarrg k>s>v>
TnakTng nge)aHBmpSay 3 លោក ម៉ក់ ឆារ៉ា CnykareTsrdm®nTT l bnkkargar k>s>v>
beckeTskBüTr 3 លោក សយ ទាស្លា RbFankarya l y k>s>v>
ykBtman ngrbft 3 លោក ហេង សុភះបញ្ញា RbFankarya l y k>s>v>





ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទ ០២៣ ២១១ ៩៤៣ , ០១៦ ៣០៧ ៣៣០

ទូរសារ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in